# សេចក្តីប្រកាសសិទ្ធិឯកជនរបស់អ្នកបោះឆ្នោត

1. អ្នកមានសិទ្ធិបោះឆ្នោត បើសិនជាអ្នក បានចុះឈ្មោះបោះឆ្នោតមានសុពលភាព ។

   អ្នកចុះឈ្មោះបោះឆ្នោតមានសុពលភាពគឺមានន័យថាជាពលរដ្ឋអាមេរិកាំងដែលជាគេហជនរស់នៅក្នុងសហរដ្ឋអាមេរិក ហើយដែលគេយ៉ាងហោចណាស់មានអាយុ 18 ឆ្នាំ ហើយមិនជាប់ពន្ធនាគារ ឬដោះលែងឲ្យនៅក្រៅឃុំដោយមានលក្ខខណ្ឌសំរាប់ការជាប់ទោសឧក្រិដ្ឋ ហើយដែលបានចុះឈ្មោះឆ្នោតនៅតាមអាសយដ្ឋានបច្ចុប្បន្នរបស់គេ។

2. អ្នកមានសិទ្ធិបោះឆ្នោតលើសន្លឹកឆ្នោតបណ្តោះអាសន្ន បើសិនជាឈ្មោះរបស់អ្នកមិនមាននៅក្នុង បញ្ជីបោះឆ្នោត ។

3. អ្នកមានសិទ្ធិបោះឆ្នោត បើសិនជាអ្នក មានវត្តមាន ហើយនៅក្នុងជួរចាំបោះឆ្នោតតាមការិយាល័យបោះឆ្នោត មុនពេល ការិយាល័យបោះឆ្នោតនោះបិទទ្វារ។

4. អ្នកមានសិទ្ធិបោះឆ្នោតជាសំងាត់ដោយគ្មានការគំរាមកំហែង។

5. អ្នកមានសិទ្ធិទទួលសន្លឹកឆ្នោតថ្មី បើសិនជា មុនពេលបោះឆ្នោតរបស់អ្នក អ្នកដឹងថាអ្នកបានគូសខុស។

   បើសិនជា ពេលណាក៏ដោយ មុនពេលអ្នកដាក់សន្លឹកឆ្នោតចូលក្នុងប្រអប់ អ្នកមានអារម្មណ៍ថា អ្នកបានគូសខុស អ្នកមានសិទ្ធិដូរសន្លឹកឆ្នោតដែលខូចជាមួយសន្លឹកឆ្នោតល្អថ្មីវិញបាន។ អ្នកបោះឆ្នោតតាមសំបុត្រក៏អាចសុំ ហើយទទួលសន្លឹកឆ្នោតថ្មី បើសិនជាគេផ្ញើសន្លឹកឆ្នោតខូចនោះមកឲ្យមន្ត្រីរៀបចំការបោះឆ្នោតបានមុនពេលគេបិទទ្វារការិយាល័យបោះឆ្នោតនៅថ្ងៃបោះឆ្នោត។

6. អ្នកមានសិទ្ធិទទួលជំនួយ ក្នុងការបោះ ឆ្នោតរបស់អ្នក បើសិនជាអ្នកមិនអាច បោះបានដោយគ្មានជំនួយ ។

7. អ្នកមានសិទ្ធិផ្ញើសន្លឹកឆ្នោតបោះតាមសំបុត្រគូសរួចហើយទៅមណ្ឌលបោះឆ្នោតមួយណាក៏បានដែរនៅក្នុងខោនធី។

8. អ្នកមានសិទ្ធិទទួលសម្ភារៈបោះឆ្នោតជាភាសាផ្សេងទៀត បើសិនជាមានគេហជនគ្រប់គ្រាន់រស់នៅក្នុងមណ្ឌលបោះឆ្នោតដែលអាចធានានូវផលិតផល។

9. អ្នកមានសិទ្ធិសួរសំនួរអំពីនិតិវិធីបោះឆ្នោត និងសង្កេតមើលដំណើរការបោះឆ្នោត។

   អ្នកមានសិទ្ធិសួរសំនួរទៅ ក្រុមប្រឹក្សាមណ្ឌល និងមន្ត្រីរៀបចំការបោះឆ្នោតអំពីនិតិវិធីបោះឆ្នោតនិងទទួលចំឡើយ ឬបង្វែរសំនួរទៅមន្ត្រីរៀបចំការបោះឆ្នោតដើម្បីឲ្យគេឆ្លើយ។ ក៏ប៉ុន្តែ បើសិនជាសំនួរដដែលៗ រំខានកិច្ចប្រតិបត្តិការក្នុងការងាររបស់គេក្រុមប្រឹក្សា ឬមន្ត្រីរៀបចំការបោះឆ្នោតអាចផ្តាច់ការឆ្លើយតបតនឹងសំនួរ។

10. អ្នកមានសិទ្ធិរាយការណ៍នូវសកម្មភាពខុសច្បាប់ ឬកេងបន្លំណាមួយទៅកាន់មន្ត្រីរៀបចំការបោះឆ្នោតតាមមូលដ្ឋាន ឬទៅការិយាល័យលេខាធិការរដ្ឋ។

---

**បើសិនជាអ្នកជឿថាអ្នកត្រូវគេបដិសេធសិទ្ធិទាំងឡាយនេះ ឬអ្នកដឹងថាមានការកេងបន្លំ ឬប្រព្រឹត្តិមិនត្រឹមត្រូវ សូមទូរស័ព្ទមកបណ្តាញលាក់ការពិសេសរបស់ការិយាល័យរដ្ឋលេខាធិការតាមលេខ (888) 345-4917។**

---

ព័ត៌មាននៅក្នុងសេចក្តីថ្លែងបញ្ជាក់នៃការចុះឈ្មោះបោះឆ្នោតរបស់អ្នកនិងត្រូវប្រើដោយមន្ត្រីរៀបចំការបោះឆ្នោតដើម្បីផ្ញើព័ត៌មានជាផ្លូវការអំពីដំណើរការបោះឆ្នោត ដូចជាទីកន្លែងការិយាល័យបោះឆ្នោតរបស់អ្នក និងបញ្ហា និងបេក្ខជនឈរឈ្មោះដែលនឹងមានឈ្មោះនៅក្នុងសន្លឹកឆ្នោត។ ការប្រើប្រាស់ព័ត៌មានរបស់អ្នកចុះឈ្មោះបោះឆ្នោតធ្វើពាណិជ្ជកម្មគឺត្រូវហាមឃាត់ដោយច្បាប់ហើយគឺជាទោសបទមជ្ឈិមទៀតផង។ ព័ត៌មានអ្នកបោះឆ្នោតអាចត្រូវផ្តល់ឲ្យបេក្ខជនឈរឈ្មោះដែលឈ្មោះណាម្នាក់សំរាប់ការិយាល័យ, គណៈកម្មការវិធានការសន្លឹកឆ្នោត, ឬជនផ្សេងទៀតសំរាប់ការបោះឆ្នោត, សំរាប់គោលបំណងនៃការអប់រំអ្នកប្រាជ្ញ, នៃសារព័ត៌មាន, នយោបាយ ឬរដ្ឋាភិបាល ដូចតាមការកំណត់របស់លេខាធិការរដ្ឋ។ ប័ណ្ណបើកបរ និងលេខសន្តិសុខសង្គម, ឬហត្ថលេខារបស់អ្នកដូចមានបង្ហាញនៅក្នុងប័ណ្ណចុះឈ្មោះបោះឆ្នោតរបស់អ្នកមិនអាចបញ្ចេញសំរាប់ក្នុងគោលបំណងទាំងនេះទេ។ បើសិនជាអ្នកមានសំនួរនានាអំពីការប្រើប្រាស់ព័ត៌មានអ្នកបោះឆ្នោត ឬមានគោលបំណងរាយការណ៍អំពីការមន្ទិលសង្ស័យនៃការប្រើប្រាស់ព័ត៌មាននោះពុំសមរម្យ សូមទូរស័ព្ទមកការិយាល័យរដ្ឋលេខាធិការដ្ឋបណ្តាញពិសេសសំរាប់អ្នកបោះឆ្នោតតាមលេខ (888) 345-4917។

អ្នកបោះឆ្នោតមួយចំនួនប្រឈមមុខទល់នឹងស្ថានភាពគំរាមកំហែងដល់ជីវិតអាចមានលក្ខណសម្បត្តិជាអ្នកបោះឆ្នោតលាក់ការ។ សំរាប់ព័ត៌មានថែមទៀត សូមទាក់ទងតាមទូរស័ព្ទមកការិយាល័យលេខាធិការរដ្ឋកម្មវិធីតាមផ្ទះ លេខដោយឥតគិតថ្លៃ (877) 322-5227 ឬចូលទស្សនា *www.sos.ca.gov*។